# សាជីវកម្មប្រេងកាតជាតិវៀតណាម Petrolimex

# បើកការិយាល័យតំណាងរបស់ខ្លួន នៅរាជធានីភ្នំពេញ

ដោយមើលឃើញពីសក្តានុពលសេដ្ឋកិច្ច និងលក្ខណៈអំណោយផលនៅកម្ពុជា ក៏ដូចជាការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរឡើង ស្របតាមអនុសាសន៍នៃប្រមុខថ្នាក់ដឹកនាំនៃប្រទេសទាំងពីរកម្ពុជា-វៀត ណាម សាជីវកម្មប្រេងកាតជាតិវៀតណាម Petrolimex បានបើកការិយាល័យតំណាងរបស់ខ្លួននៅកម្ពុជា នៅល្ងាច ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ដែលភាគីកម្ពុជាតំណាងដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម និងភាគីវៀតណាមតំណាងដោយឯកឧត្តម **Pham Gia Khiem** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការបរទេស ។ ពិធីបើកការិយាល័យតំណាងនៃក្រុមហ៊ុនប្រេងវៀតណាម Petrolimex នេះត្រូវបានប្រារព្ធធ្វើឡើង នៅសណ្ឋាគារ **Naga World** រាជធានីភ្នំពេញ ដោយមានភ្ញៀវជាតិ-អន្តរជាតិ ចូលរួមអបអរសាទរ និងពិសារភោជនី អាហារសាមគ្គី និងទស្សនារបាំប្រពៃណីខ្មែរយ៉ាងច្រើនកុះករ ។






លោក **Bui Ngoc Bao** អគ្គនាយកក្រុមហ៊ុនប្រេង Petrolimex បានឱ្យដឹងថាៈការិយាល័យតំនាងនេះ មានភារកិច្ចលើកកំពស់កិត្យានុភាពរបស់ក្រុមហ៊ុន ការសិក្សាស្រាវជ្រាវទីផ្សារ ព្រមទាំងស្វែងរកឱកាសពាណិជ្ជកម្ម សំរាប់ ផលិតផល ប្រេង ឧស្ម័ន និងទំនិញ ក៏ដូចជាសេវាកម្មផ្សេងៗទៀត នៅកម្ពុជា ។ លោកបានបន្តថាៈ វាជាការបោះ ជំហ៊ានដ៏សំខាន់សំរាប់យុទ្ធសាស្ត្រពង្រីកសាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងជំរុញលើកកំពស់ប្រតិបត្តិការរបស់យើង នៅលើទីផ្សារអន្តរជាតិ ជាពិសេស នៅលើទីផ្សាររបស់កម្ពុជា ។

ឯកឧត្តម **Pham Gia Khiem** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានមានប្រសាសន៍បញ្ជាក់ថាៈក្រុមហ៊ុន Petrolimex មានវត្តមាននៅកម្ពុជា តាំងពីឆ្នាំ ១៩៩០ ប្រេងដែលផលិតឡើងដោយក្រុមហ៊ុននេះ បានបំពេញតំរូវការទីផ្សារជាងពាក់កណ្តាលនៅកម្ពុជា ជាមួយនិងប្រាក់ចំណូលជាង៧០០លានដុល្លាអាមេរិក ក្នុងមួយឆ្នាំ ។

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តំណាងរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍សំដែងនូវការអបអរសាទរ ដែលក្រុមហ៊ុនប្រេង Petrolimex របស់វៀតណាម បានបើកការិយាល័យតំណាងរបស់ខ្លួននៅកម្ពុជា ។ ឯកឧត្តម បានបញ្ជាក់ថាៈក្រុមហ៊ុននេះ បានផ្គត់ផ្គង់ប្រេងដល់ក្រុមហ៊ុន ក្នុងស្រុកនៅកម្ពុជា អស់រយៈពេល២០ឆ្នាំមកហើយ ហើយប្រេងរបស់ក្រុមហ៊ុននេះមានគុណភាពល្អ និងតម្លៃអាចប្រកួតប្រជែងបាន ។ ក្នុង០១ឆ្នាំ

ប្រទេសកម្ពុជា ប្រើប្រាស់ប្រេងអស់ប្រហែល ០១លានតោន ហើយ៨០% នៃប្រេងទាំងនោះ ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុន Petrolimex ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបន្ថែមថា៖ក្រុមហ៊ុន សូគីម៉ិច និងក្រុមហ៊ុន តេលា គឺជាអតិថិជនដ៏ធំរបស់ក្រុមហ៊ុន Petrolimex សំរាប់បែងចែកនិងផ្គត់ផ្គង់ នៅកម្ពុជា ។ ឯកឧត្តមបានបន្តថា៖ការបើកការិយាល័យតំណាងនៅកម្ពុជារបស់ក្រុមហ៊ុន Petrolimex គឺជាការបោះជំហ៊ានថ្មី និងល្អសម្រាប់វិស័យប្រេងនៅកម្ពុជា ។ ឯកឧត្តម បានលើកទឹកចិត្តឱ្យក្រុមហ៊ុននេះ បើកសាខានៅកម្ពុជា ក្នុងពេលឆាប់ៗ ពីព្រោះការិយាល័យតំណាងមិនអាចចុះហត្ថលេខា លើកិច្ចសន្យាអាជីវកម្មណាមួយបានទេ គឺបានត្រឹមតែផ្សាយពាណិជ្ជកម្មជូនក្រុមហ៊ុនប៉ុណ្ណោះ ។